បទបង្ហាញរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ក្នុងសន្និបាតបូកសរុបការងារធនធានទឹកនិងឧតុនិយមរបស់ក្រសួងធនធានទឹក
និងឧតុនិយម ទូទាំងប្រទេសប្រចាំឆ្នាំ២០២៤ និងទិសដៅអនុវត្តឆ្នាំ២០២៥
សណ្ឋាគារសុខាភ្នំពេញ, ថ្ងៃទី១២-១៣ ខែកុម្ភៈ ឆ្នាំ២០២៥

# ការរួមចំណែករបស់វិស័យធនធានទឹក
# ក្នុងវិស័យកសិកម្ម


លោក   កើត កិត្តិនាថ
អគ្គលេខាធិការរង
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# មាតិកានៃបទបង្ហាញ

១. សេចក្តីផ្តើម

១.១ កម្មវិធីគោលនយោបាយអាទិភាពទី៥ និងទី៦

១.២ គោលនយោបាយនិងយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម២០២៤-២០២៨

២. ការចូលរួមចំណែករបស់វិស័យធនធានទឹក

២.១ សារៈសំខាន់នៃធនធានទឹកសម្រាប់វិស័យកសិកម្ម

២.២ សមិទ្ធផលសំខាន់ៗឆ្នាំ២០២៤

៣. បញ្ហាប្រឈមចម្បង

៤. ទិសដៅការងារកសិកម្មនិងធនធានទឹក

៥. សន្និដ្ឋាន និងសំណូមពរ

៥.១ សន្និដ្ឋាន

៥.២ សំណូមពរ

# ១. សេចក្តីផ្តើម

- រាជរដ្ឋាភិបាលតែងតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ដែលចូលរួមចំណែកក្នុងការធានាសន្តិសុខស្បៀង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

- ផ្អែកតាមទិន្នន័យឆ្នាំគោលថ្មី ក្នុងឆ្នាំ២០២៤កន្លងមកនេះ ទៅវិស័យកសិកម្មបន្តចូលរួមចំណែកប្រមាណ ១៦,៧% នៃផលិតផលសរុបក្នុងស្រុក កើនឡើង ៣១ទ្រីលានរៀល (ប្រមាណ ៧,៨២ពាន់លានដុល្លារ) ធៀបនឹងឆ្នាំ២០២៣មាន ២៩ទ្រីលានរៀល (ប្រមាណ ៧,២៥ពាន់លានដុល្លារ). ជាការរួមចំណែករបស់ អនុវិស័យនានារួមមាន ផ្នែកដំណាំ ៦១,៣% ផ្នែកជលផល ២០% ផ្នែកផលិតកម្មសត្វ ១៥,៤% និងផ្នែកព្រៃឈើ ៣,៣%។

- វិស័យកសិកម្មជួបប្រទះបញ្ហាមួយចំនួនដូចជា កង្វះបច្ចេកទេសទំនើប ប្រព័ន្ធស្រោចស្រពមិនទាន់គ្រប់គ្រាន់ ថ្លៃដើមផលិតកម្មខ្ពស់ជាដើម កង្វះទីផ្សារ ការធ្លាក់ចុះថ្លៃកសិផល កង្វះទុនវិនិយោគ ការដឹកជញ្ជូនមានតម្លៃខ្ពស់ និងបម្រែបម្រួលអាកាសធាតុ ។




# ១.១ កម្មវិធីគោលនយោបាយអាទិភាពទី៥ និងទី៦

## កម្មវិធីនយោបាយអាទិភាពសម្រាប់វិស័យកសិកម្ម

### ការលើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផល តាម រយៈកម្មវិធីហិរញ្ញប្បទាន

- លើកស្ទួយផលិតកម្មកសិកម្មប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច
- ពង្រឹងគុណភាព សុវត្ថិភាព និងស្តង់ដាផលិតកម្មឆ្លើយតបនឹងទីផ្សារនិងការនាំចេញ
- រក្សាលំនឹងថ្លៃកសិផល តាមរយៈការធ្វើផែនការផលិតកម្មតាមតម្រូវការនិងការផ្គត់ផ្គង់

### ការដាក់ពង្រាយមន្ត្រីកសិកម្ម ឃុំ-សង្កាត់

- ការសម្របសម្រួលនិងកិច្ចសហការរវាងថ្នាក់ដឹកនាំនិងមូលដ្ឋាន
- ផ្តល់បច្ចេកទេសកសិកម្មទៅកសិករ
- ដឹកនាំសម្របសម្រួលទីផ្សារតាមរយៈការអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម
- ផ្តល់ព័ត៌មានពីបញ្ហានៅមូលដ្ឋានសម្រាប់ការអន្តរាគមន៍ទាន់ពេលវេលា

### ការអភិវឌ្ឍសហគមន៍ទំនើប

- ជាសហគ្រាសសេដ្ឋកិច្ចកសិកម្មដ៏រឹងមាំ មានសមាហរណកម្មខ្ពស់ មានសេដ្ឋកិច្ចមាត្រដ្ឋាន មានសមត្ថភាពប្រកួតប្រជែងទាំងបរិមាណនិងគុណភាព
- ការទទួលបានការគាំទ្រ បច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធ ដើមទុន និងទីផ្សារ

# ១.២ គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០២៤-២០២៨

## ១.២.១ ចក្ខុវិស័យ

បន្តធានាសន្តិសុខស្បៀងកម្ពុជាប្រកបដោយ និរន្តរភាព សេដ្ឋកិច្ច និងបរិស្ថាន ហើយកសិកម្មនៅតែចូលរួមចំណែកយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចជាតិ។

**ចក្ខុវិស័យកសិកម្ម ៖**

មានហូប(**សន្តិសុខស្បៀង**) មានប្រើ(**សម្បូរបែប**) មានបាន(**ប្រាក់ចំណូល**) និងមានរហូត(**និរន្តរភាព**)

- មិនជំរុញផលិតកម្មកសិកម្ម ដោយគ្មានប្រសិទ្ធភាពសេដ្ឋកិច្ច និងជួបប្រទះបញ្ហាទីផ្សារនោះទេ
- ការធ្វើកសិកម្មត្រូវមានប្រសិទ្ធភាពសេដ្ឋកិច្ច ត្រូវមានទីផ្សារ (គុណភាព សុវត្ថិភាព ស្តង់ដារ) និងមាននិរន្តរភាព
- ការរៀបចំប្រព័ន្ធស្រោចស្រពគួរតម្រង់ទិសដល់ចំណុចទី២ខាងលើឱ្យចំទិសដៅ។

## ១.២ គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០២៤-២០២៨ (ត)

### ១.២.២ បេសកកម្ម

ដឹកនាំវិស័យកសិកម្ម ដើម្បីសម្រេចចក្ខុវិស័យខាងលើ តាមរយៈការស្រាវជ្រាវ និងផ្តល់បច្ចេកទេសកសិកម្ម គ្រប់គ្រងធនធានធម្មជាតិ បណ្តុះបណ្តាលធនធានមនុស្ស កសាងនិងពង្រឹងមូលដ្ឋានគតិយុត្តកសិកម្ម និងដាក់ចេញវិធានការសេដ្ឋកិច្ចដើម្បីគាំទ្រ សម្របសម្រួល និងតម្រង់ទិសខ្សែច្រវាក់ផលិតកម្ម។

### ១.២.៣ គោលបំណង

ពង្រឹងប្រសិទ្ធភាពខ្សែច្រវាក់ផលិតកម្មកសិកម្មប្រកបដោយនិរន្តរភាពដើម្បីធានាសន្តិសុខស្បៀងនិងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ។

### ១.២.៤ យុទ្ធសាស្ត្រ

- យុទ្ធសាស្ត្រសម្រាប់កសាងសហគមន៍កសិកម្មទំនើប
- យុទ្ធសាស្ត្រសម្រាប់សេវាទ្រទ្រង់បច្ចេកទេសកសិកម្មបានទៅដល់កសិករ
- យុទ្ធសាស្ត្រសម្រាប់រក្សាលំនឹងថ្លៃកសិផលសំខាន់ៗ
- យុទ្ធសាស្ត្រសម្រាប់ថែរក្សា និងគ្រប់គ្រងធនធានធម្មជាតិកសិកម្ម។

# ២. ការចូលរួមចំណែករបស់វិស័យធនធានទឹក

## ២.១.១ សារៈសំខាន់នៃធនធានទឹកសម្រាប់អនុវិស័យ ផ្នែកដំណាំ

- បង្កើនកម្រិតនៃការដុះលូតលាស់របស់ដំណាំ
- ជួយធ្វើប្រពលវប្បកម្ម និងពិពិធកម្មដំណាំ
- ជួយបង្កើនរដូវដាំដុះដំណាំ
- ជួយកែលម្អរចនាសម្ព័ន្ធដី
- ជួយបង្កើនប្រសិទ្ធភាពជីកសិកម្ម
- ជួយបង្កើនទិន្នផលដំណាំ និងគុណភាពផលិតផល
- ជួយរក្សាស្ថិរភាពស្បៀង។
- ជួយបង្កើនប្រាក់ចំណូលពីការដាំដុះ



ការគ្រប់គ្រងធនធានទឹក និងការចែកចាយទឹកឱ្យដល់ស្រែចម្ការជាការចាំបាច់ណាស់!

# ២. ការចូលរួមចំណែករបស់វិស័យធនធានទឹក (ត)

## ២.១.២ សារៈសំខាន់នៃធនធានទឹកសម្រាប់អនុវិស័យ ផ្នែកជលផល

- ជួយជាប្រភពផលិតផលត្រី (ធានាសន្តិសុខស្បៀងនិងអាហាររូបត្ថម្ភ)
- ជាទីជម្រកវារីសត្វ និងប្រព័ន្ធអេកូឡូស៊ី
- ជួយសម្រាប់ការអភិវឌ្ឍវារីវប្បកម្ម
- ជួយដល់អេកូទេសចរណ៍ធម្មជាតិ
- ជួយកាត់បន្ថយការប្រែប្រួលបរិស្ថាន និងអាកាសធាតុ
- ជួយបង្កើនប្រាក់ចំណូលពីផលនេសាទ












# ២.២ សមិទ្ធផលសំខាន់ៗឆ្នាំ២០២៤

## បរិមាណផលដំណាំឆ្នាំ២០២០-២០២៤




| | 2020 | 2021 | 2022 | 2023 | 2024 |
|---|---|---|---|---|---|
| បរិមាណផលកៅស៊ូ | 349,300 | 368,000 | 382,000 | 391,800 | 407,209 |
| បរិមាណផលដំណាំសាកវប្បកម្ម | 3,684,750 | 4,365,878 | 4,421,375 | 4,964,959 | 5,152,789 |
| បរិមាណផលស្រូវ | 10,935,618 | 12,206,911 | 11,623,871 | 12,492,697 | 13,889,562 |
| បរិមាណផលដំណាំឧស្សាហកម្ម | 15,091,454 | 19,158,995 | 18,668,106 | 18,960,411 | 20,052,019 |
| សរុប | 30,061,122 | 36,099,783 | 35,095,352 | 36,809,867 | 39,501,579 |

# ២.២ សមិទ្ធផលសំខាន់ៗឆ្នាំ២០២៤ (ត)

**ផលផលផលសរុប = ៩២៦ ៩៣៤តោន កើនឡើង ៦០ ៦៨៤តោន ស្មើនឹង៧%**

➢ ផលនេសាទទឹកសាប = **៤៦៧ ៣៤៤តោន**, ផលនេសាទសមុទ្រ = **១៣៩ ៣១០តោន**, ផលវារីវប្បកម្ម = **៣២០ ២៨០**តោន



# ៣.បញ្ហាប្រឈមចម្បង

- ប្រព័ន្ធស្រោចស្រពទឹក នៅមិនទាន់គ្រប់គ្រាន់ គឺនៅខ្វះប្រព័ន្ធប្រឡាយទី៣ និងប្រឡាយជើងក្អែប នាំទឹកចូលស្រែ ចម្ការ សម្រាប់ការធ្វើប្រពលវប្បកម្មនិងពិពិធកម្មកសិកម្ម
- ការប្រែប្រួលអាកាសធាតុ បង្កឱ្យមានគ្រោះរាំងស្ងួត ទឹកជំនន់លិចផលដំណាំ ការធ្លាក់ចុះគុណភាពដី និងប្រែប្រួលរបបទឹកទន្លេ ធ្វើប៉ះពាល់ដល់ធនធានជលផល និងជីវចម្រុះ
- ការបន្សុីគ្នានៃការរៀបចំផែនការនិងការអភិវឌ្ឍន៍កសិកម្មរៀបរយ របស់ក្រុមការងារបច្ចេកទេសចម្រុះកសិកម្មនិងទឹក នៅមានកម្រិត
- ត្រូវការហេដ្ឋារចនាសម្ព័ន្ធទឹក សម្រាប់វារីវប្បកម្ម ទឹកសាប និងសមុទ្រ

# ៤. ទិសដៅការងារកសិកម្មនិងធនធានទឹក

**អភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពកសិកម្មឱ្យបានរៀបរយ**

- កែលម្អប្រព័ន្ធធារាសាស្ត្រឱ្យកាន់តែមានប្រសិទ្ធភាពសម្រាប់ការស្រោចស្រពនៅតំបន់ដាំដុះតាមតម្រូវការជាក់ស្តែងនៃរដូវនីមួយៗ
- កំណត់តំបន់ដាំដុះដែលងាយរងគ្រោះដោយទឹកជំនន់និងរាំងស្ងួត ដើម្បីរៀបចំប្រព័ន្ធស្រោចស្រពនិងប្រព័ន្ធរំដោះទឹកឱ្យមានប្រសិទ្ធភាព

**ធ្វើប្រពលវប្បកម្មនិងពិពិធកម្មដំណាំ**

- រៀបចំប្រព័ន្ធស្រោចស្រពដែលអាចធានាបាននូវប្រសិទ្ធភាពសម្រាប់ធ្វើប្រពលវប្បកម្មដំណាំ
- រៀបចំប្រព័ន្ធស្តុកទឹកនិងស្រោចស្រពសម្រាប់អនុវត្តពិពិធកម្មដំណាំនៅតំបន់ដែលខ្វះទឹក

**គ្រប់គ្រងទឹកនៅក្នុងសហគមន៍កសិកម្ម**

- ផ្តល់អាទិភាពក្នុងការរៀបចំប្រព័ន្ធស្រោចស្រពឱ្យបានពេញលេញ ដើម្បីគាំទ្រដល់សហគមន៍កសិកម្មទំនើប
- រៀបចំសហគមន៍ប្រើប្រាស់ទឹកនិងសហគមន៍កសិកម្មគួរជាសហគមន៍តែមួយធ្វើការជាមួយគ្នា

# ៤. ទិសដៅការងារកសិកម្មនិងធនធានទឹក (ត)

- ជំរុញយន្តការអនុវត្តន៍ការងារ របស់ក្រុមការងារបច្ចេកទេសចម្រុះកសិកម្មនិងទឹក ក៏ដូចជាក្រុមការងារត្រី-វិស័យ កសិកម្ម-ទឹក-ជនបទ ឱ្យកាន់តែមានប្រសិទ្ធភាព

- ពង្រឹងកិច្ចសហការឱ្យកាន់តែជិតស្និទក្នុងការអនុវត្តគម្រោងពាក់ព័ន្ធនឹងវិស័យកសិកម្មនិងធនធានទឹក
- ធ្វើផែនការផលិតកម្មកសិកម្ម តាមតំបន់ដែលមានប្រភពទឹក និងកំណត់លទ្ធភាពដែលអាចស្រោចស្រពបាន ជាពិសេសនៅរដូវប្រាំង

- ពិនិត្យលទ្ធភាពបង្កើតស្ថានីយបូមទឹក ប្រព័ន្ធស្រោចស្រពបង្វៀរ និងប្រព័ន្ធរំដោះទឹក ជាពិសេសនៅតំបន់មានហានិភ័យទឹកជំនន់
- ពិនិត្យលទ្ធភាពកសាងប្រព័ន្ធស្រោចស្រពដល់ស្រែ ចម្ការ តាមតំបន់សក្តានុពលផលិតកម្មដំណាំសំខាន់ៗ នឹងប្រព័ន្ធនាំទឹកសម្រាប់វារីវប្បកម្ម។

# ៥. សន្និដ្ឋាន និងសំណូមពរ

## ៥.១ សន្និដ្ឋាន

ការអភិវឌ្ឍប្រព័ន្ធស្រោចស្រពបានគាំទ្រដល់កំណើនផលិតកម្មកសិកម្ម និងបង្កើនប្រាក់ចំណូលប្រជាកសិករ និង សេដ្ឋកិច្ចជាតិ ទោះជានៅជួបប្រទះបញ្ហាខ្លះៗពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹក

## ៥.២ សំណូមពរ

- សូមឱ្យក្រសួងធនធានទឹកនិងឧតុនិយមជួយផ្តល់ទិន្នន័យប្រព័ន្ធអាងស្តុកទឹកប្រមាណជាង២៦០០កន្លែង នូវប្រព័ន្ធប្រឡាយតូច ធំ បរិមាណទឹកដែលអាចស្រោចស្រពនៅរដូវ និងវស្សា និងផែនទីប្រព័ន្ធស្រោចស្រពដីកសិកម្ម
- ស្នើអភិវឌ្ឍន៍បន្ថែមនូវប្រព័ន្ធស្តុកទឹក តាមស្ទឹង ព្រែក និងបឹងធម្មជាតិនានា
- ពង្រឹងកិច្ចសហការឱ្យកាន់តែជិតស្និទ្ធក្នុងការអនុវត្តគម្រោងពាក់ព័ន្ធនឹងវិស័យកសិកម្ម និងវិស័យធនធានទឹក
- បង្កើនកិច្ចសហការឱ្យបានជិតស្និទ្ធក្នុងការសិក្សារៀបចំ និងអនុវត្តការងារបច្ចេកទេសចម្រុះកសិកម្មនិងទឹក
- ស្នើរៀបចំប្រព័ន្ធស្រោចស្រពឱ្យបានពេញលេញនៅប៉ូលសេដ្ឋកិច្ចទី៤ (របៀងមច្ឆា និងស្រូវអង្ករ) នៅក្នុខេត្តចំនួន៤ គឺ ខេត្តពោធិ៍សាត់ បាត់ដំបង ប៉ៃលិន និងខេត្តបន្ទាយមានជ័យ។

# សូមអរគុណ